# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែធ្នូ ឆ្នាំ២០១៤
## និងទិសដៅការងារ ខែមករា ឆ្នាំ២០១៥

(ពីថ្ងៃទី២៦/១១/២០១៤ ដល់ ២៥/១២/២០១៤)

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី២ឆ្នាំ២០១៤ និងទិសដៅការងារដែលបានដាក់ចេញកាលពីខែវិច្ឆិកាឆ្នាំ២០១៤កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

# I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែធ្នូឆ្នាំ២០១៤នេះ មានការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានប្រតិបត្តិការដោយ មន្ទីរប្រឆាំងគ្រឿងញៀន និងស្នងការដ្ឋាននគរបាល, បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្តចំនួន ១៨ គឺ ៖ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ចាម, កំពង់ឆ្នាំង, សៀមរាប, កំពង់ធំ, បាត់ដំបង, បន្ទាយមានជ័យ, ស្ទឹងត្រែង, រតនគិរី, ស្វាយរៀង, ព្រៃវែង, ក្រចេះ, ពោធិសាត់ និង ខេត្តត្បូងឃ្មុំ ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយអង្គភាពជំនាញ និងស្នងការដ្ឋាននគរបាល, កងរាជអាវុធហត្ថរាជធានី ខេត្តខាងលើ មានបទល្មើសពីរករណីធំៗដែលបង្ក្រាបដោយកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន ព្រមទាំងចាប់យកគ្រឿងញៀនសំយោគប្រភេទ មេតំហ្វេតាមីនក្រាមម្សៅ ចំនួន ១.៥៩៦,០២ ក្រាម និង ហេរ៉ូអ៊ីនចំនួន ១.០៤៩,៣៩ ក្រាម ។

# II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *១. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំលើការងារជាគោលសំខាន់ៗ មានជាអាទិ៍ ៖

- ជំរុញការរៀបចំពិនិត្យ និងវាយតម្លៃជ្រើសរើសផ្ទាំងគំនូរជ័យលាភី ដើម្បីប្រកាសលទ្ធផលនិងផ្តល់រង្វាន់

ដល់សិស្សជ័យលាភី ដែលពូកែគូរគំនូរប្រឆាំងគ្រឿងញៀន នៅខេត្តកោះកុង នាថ្ងៃទី ២៨-២៩ ខែធ្នូ ឆ្នាំ ២០១៤

- បន្តការពិភាក្សាលើខ្លឹមសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងជាមួយដៃគូពាក់ព័ន្ធនានា (ការអប់រំត្រូវមានឯកសារ ឧបករណ៍ សម្ភារៈដើម្បីឱ្យសិស្សឆាប់យល់ដឹង និងងាយទទួលយកបាន)
- បន្តជំរុញការពិភាក្សារៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន)
- អនុញ្ញាតឱ្យ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមជាអធិបតីក្នុងពិធីប្រគេនសៀវភៅ ៣៦៥ កវី ភាគទី៣ និងខួប៤ឆ្នាំ នៃការបង្កើតសមាគមទ្រទ្រង់ការបោះពុម្ពនិងអប់រំ
- ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅខេត្តបន្ទាយមានជ័យ សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផលនៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- ជំរុញការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាពដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញការរៀបចំកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ ឱ្យបានឆាប់រហ័ស
- ជំរុញឱ្យអនុគណៈកម្មការអប់រំ នៃគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត អំពីកម្មវិធីផ្តល់សេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងរបស់អង្គការមិត្តសំឡាញ់
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួងសុខាភិបាល គណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ត្រូវសហការគ្នាឱ្យបានជិតស្និទ្ធថែមទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាល (អង្គការ ខាន់ណា អង្គការមិត្តសំឡាញ់ ។ល។) និងចុះពន្យល់ណែនាំ បកស្រាយឱ្យមានការយល់ដឹងច្បាស់លាស់ថែមទៀតពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីម្ទុល/ស៊ីរ៉ាំង
- បន្តជំរុញការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាអ្នកញៀនគ្រឿងញៀននៅក្នុងពន្ធនាគារ
- រៀបចំប្រជុំដកបទពិសោធន៍ លើករណីជួញដូរគ្រឿងញៀនដែលបង្ក្រាបកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ និងការប្រើប្រាស់គ្រឿងញៀននៅតាមផ្ទះសំណាក់
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការ និង តុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ផ្ញើលិខិតស្នើសុំទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យលទ្ធភាពក្នុងការបំពេញបន្ថែមក្របខណ្ឌនគរបាលនៅថ្នាក់ប៉ុស្តិ៍រដ្ឋបាល
- បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ជាមួយក្រសួងយុត្តិធម៌

- សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ធ្វើសម្រង់ទិន្នន័យឧប្បត្តិហេតុនៃបទល្មើសនានា (ទាំងបទឧក្រិដ្ឋ បទរំលោភបំពាន អំពើហឹង្សា អំពើអនាចារ លួចឆក់ប្លន់ ។ល។) ក្នុងឆ្នាំ២០១៤ ដែលបានកើតឡើងដោយសារគ្រឿងញៀន និងបទល្មើសគ្រឿងញៀនដែលប្រព្រឹត្តដោយ ឬពាក់ព័ន្ធនឹងនគរបាលយោធា
- ជំរុញការអនុវត្តវិធានការទប់ស្កាត់ ការផលិត ការជួញដូរ ការប្រើប្រាស់គ្រឿងញៀននៅថ្នាក់មូលដ្ឋានឱ្យបានសកម្មដូចភ្លៀងរលឹម
- បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្រ្តព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- ប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តតាមដានការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ២. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ២.១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

នៅក្នុងខែធ្នូនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែវិច្ឆិកា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត នៅតែបន្តអនុវត្តកម្មវិធីអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ តាមរយៈស្ថានីយវិទ្យុជាតិ វិទ្យុរាជធានីខេត្តរបស់ខ្លួន តាមកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន ។

ដោយឡែក ការអប់រំពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ ក្រៅពីការចូលរួមដោយក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក៏មានការចូលរួមអប់រំផ្សព្វផ្សាយដោយខេត្តចំនួនពីរ គឺខេត្តបាត់ដំបង និង ខេត្តប៉ៃលិន ។

លទ្ធផលជារួម មានមហាជនចូលរួមប្រមាណ **៦៣.២០៦** នាក់ លើ **២០៨.៧៩៦** នាក់ នៃខែវិច្ឆិកា ឆ្នាំ២០១៤ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១) ។

ក្នុងចំណោមសកម្មភាពការងារដែលបានអនុវត្តខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តលើការងារមួយចំនួនដូចតទៅ :

- រៀបចំពិនិត្យ និងវាយតម្លៃជ្រើសរើសផ្ទាំងគំនូរជ័យលាភី ដើម្បីប្រកាសលទ្ធផលនិងផ្តល់រង្វាន់ជ័យលាភីដល់សិស្សពូកែគូរគំនូរប្រឆាំងគ្រឿងញៀន នៅខេត្តកោះកុង នាថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០១៤
- ចូលរួមជាអធិបតីក្នុងពិធីប្រគេនសៀវភៅ ៣៦៥ ករី ភាគទី៣ និងខួប៤ឆ្នាំនៃការបង្កើតសមាគមទ្រទ្រង់ការបោះពុម្ពនិងអប់រំ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤

- រៀបចំចាត់ចែង សម្របសម្រួលនិងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីផ្សាយផ្ទាល់របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១៤ តាមកម្មវិធី និងប្រធានបទ ដូចខាងក្រោម ៖
  - កម្មវិធីសុវត្ថិភាពអ្នក ក្រោមប្រធានបទ **តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យយុវជនចៀសផុតពីគ្រឿងញៀន**
  - កម្មវិធីចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទ **ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន**
  - កម្មវិធីសភាអ៊ីនធឺណែត ក្រោមប្រធានបទ " **លទ្ធផល និងសកម្មភាពត្រួតពិនិត្យគ្រឿងញៀនក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ** "

ជាមួយនេះ តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រចាំ**ខែធ្នូ** មានប្រិយមិត្តចូលអានចំនួន **២៥.៣៤២** ដង លើ **២៥.៧២៤** ដង នៃខែវិច្ឆិកា ឆ្នាំ២០១៤ ។

## ***២.២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន***

### ***២.២.១. ការកាត់បន្ថយគ្រោះថ្នាក់***

- បានចូលរួមសិក្សាស្រាវជ្រាវស្វែងរកចំណុចខ្វះខាត ខាងគោលនយោបាយទាក់ទងនឹងការត្រួតពិនិត្យគ្រឿងញៀន ជាមួយនឹងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រឿងញៀន និងអេដស៍
- បានអនុញ្ញាតឱ្យអង្គការមិត្តសំឡាញ់បន្តអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង លើកទី១០ (ពីថ្ងៃទី០១/០១/២០១៥ ដល់ថ្ងៃទី៣១/ ១២/២០១៥)
- បានចូលរួមក្នុងពិធីប្រគល់-ទទួលសម្ភារៈ និងពិធីបិទកម្មវិធីគម្រោង HAARP នៅកម្ពុជា កាលពីថ្ងៃទី ១៩/១២/២០១៤
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសមិទ្ធផលដែលសម្រេចបាន និងការបញ្ចប់គម្រោងកម្មវិធីដែលគាំទ្រដោយកម្មវិធីជំនួយអូស្ត្រាលី តាមរយៈកម្មវិធីអេដស៍ប្រចាំតំបន់អាស៊ី (HAARP) នៅកម្ពុជា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ ។

ក្រៅពីការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបញ្ជូនតំណាងទៅចូលរួមដំណើរទស្សនកិច្ចសិក្សាលើការងារកាត់បន្ថយគ្រោះថ្នាក់ នៅសាធារណរដ្ឋប្រជាមានិតចិន ពីថ្ងៃទី១៥-១៩ ខែធ្នូ ឆ្នាំ២០១៤ ។

### ***២.២.២. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយជនរងគ្រោះដោយគ្រឿងញៀន នៅមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជីវិតថ្មីភ្នំបាក់ និង មណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់កងរាជអាវុធហត្ថ នៅខេត្តបន្ទាយមានជ័យ (ថ្ងៃទី០៨/១២/២០១៤), មណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនពិភពនៃក្តីសង្ឃឹម និងមណ្ឌលរបស់កងរាជអាវុធហត្ថ នៅខេត្តបាត់ដំបង (ថ្ងៃទី១០/១២/២០១៤)
- ចូលរួមក្នុងកម្មវិធីវាយតម្លៃសេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ នៅមណ្ឌលសុខ

ភាព និងមន្ទីរពេទ្យបង្អែក នៅខេត្តបាត់ដំបង, បន្ទាយមានជ័យ និងសៀមរាប កាលពីថ្ងៃទី១០-១៣/ធ្នូ/២០១៤

- ចូលរួមសិក្ខាសាលា ស្តីពីការពិគ្រោះយោបល់ជាមួយមន្ត្រីអនុវត្តន៍សកម្មភាព ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ថ្ងៃទី១៦/១២/២០១៤) នៅមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលមានសមាសភាពពាក់ព័ន្ធចូលរួម **៥៥** នាក់
- សហការជាមួយក្រសួងសុខាភិបាល បន្តរៀបចំកិច្ចប្រជុំថ្នាក់សង្កាត់ ស្តីពីការអនុវត្តការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ក្នុងខណ្ឌចំនួន ០៦ នៃរាជធានីភ្នំពេញ គឺ ខណ្ឌមានជ័យ ខណ្ឌ ចំការមន ខណ្ឌទួលគោក ខណ្ឌដូនពេញ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ សរុបមានចំនួន ១៦ សង្កាត់ (ស្ទឹងមានជ័យ, ផ្សារដើមថ្កូវ, ទួលទំពូង១, ទួលទំពូង២, ទំបន់ទឹក, បឹងត្របែក, ទឹកល្អក់ ២, វត្តភ្នំ, ស្រះចក, ផ្សារចាស់, ផ្សារកណ្តាល១, ផ្សារកណ្តាល២, ចោមចៅ, ឃ្មួញ, ភ្នំពេញថ្មី និង សង្កាត់ទឹកថ្លា ដែលមានសមាភាពចូលរួមក្នុងមួយសង្កាត់ ៣០ នាក់ (សរុប **៤៨០** នាក់) ។

## ២.៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- បន្តបើកវគ្គផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន ជូនដល់កងយោធពលខេមរភូមិន្ទយោធភូមិភាគទី១ ខេត្តស្ទឹងត្រែង នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ ចំនួន ២០០ នាក់, យោធភូមិភាគទី២ ខេត្តកំពង់ចាម នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ ចំនួន ៦០ នាក់ (សរុប **២៦០** នាក់)
- ចូលរួម និងផ្តល់គ្រូឧទ្ទេសសម្រាប់វគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ នៅតាមអាកាសយានដ្ឋានអន្តរជាតិ ស្តីពីវិធានការប្រយុទ្ធប្រឆាំងការ ជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ដែលរៀបចំដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និង មានសិក្ខាកាមចូលរួម **៥៧** នាក់ ។

ក្រៅពីការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- ចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ០១ រូប និងសម្របសម្រួលជូនតំណាងសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ០១ រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិច ពីថ្ងៃទី០៩-១២ ខែធ្នូ ឆ្នាំ ២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ
- ចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តច្បាប់អាស៊ាន បូក ៣ ស្តីពីការប្រឆាំងថ្នាំញៀន ATS និងសារធាតុផ្សេងៗទៀត ដែលនឹងប្រព្រឹត្តទៅនៅ ប្រទេសថៃ នាថ្ងៃទី១៩-៣០ ខែមករា ឆ្នាំ២០១៤ ។

ដោយឡែក ក្រសួងការពារជាតិ តាមរយៈគ្រូបង្គោលដែលបានទទួលវគ្គបណ្តុះបណ្តាលរួចហើយ បានយកចំណេះដឹងនេះ ទៅបណ្តុះបណ្តាលបន្តដល់មន្ត្រីកងយោធពលខេមរភូមិន្ទ នៅតាមយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករង និងអង្គភាពចំណុះនានា បានចំនួន ២១ លើក មានមន្ត្រីចូលរួមសរុប **៣.៨៣៥** នាក់ ។

ទន្ទឹមនឹងការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀន សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

- បទល្មើសគ្រឿងញៀន សរុប **១៩៧ ករណី** លើ ១៤៥ ករណី នៃខែវិច្ឆិកា ឆ្នាំ២០១៤
- ជនសង្ស័យ ឃាត់ខ្លួន សរុប **៤១៦ នាក់** លើ ៣៤៨ នាក់ នៃខែវិច្ឆិកា ឆ្នាំ២០១៤

ក្នុងចំនួនបទល្មើសគ្រឿងញៀន **១៩៧ ករណី** និង ជនសង្ស័យទាំង **៤១៦ នាក់** (ស្រី ៥២ នាក់) ខាងលើគឺ :

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចនគរបាលជាតិ **១៤១ ករណី**, ជនសង្ស័យ **២៥៦ នាក់** (ស្រី ៣៣ នាក់)
- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថ **៥៦ ករណី**, ជនសង្ស័យ **១៦០ នាក់** (ស្រី ១៩ នាក់)

ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ៤១៦ នាក់ ខាងលើ មាន ០៣ សញ្ជាតិ គឺ ខ្មែរ ២៤០ នាក់ (ស្រី ២៦ នាក់), វៀតណាម ១៤ នាក់ (ស្រី ០៦ នាក់), ឡាវ ០២ នាក់ (ស្រី ០១នាក់) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** មេតំហ្វេតាមីន WY ៣៩៧,៣១ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ ICE ២.១៧២,៧៥ ក្រាម, ហេរ៉ូអ៊ីន ១០៥៧,៤៦ ក្រាម និងដើមក្រៀម ១១ ដើម
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** ដែលបានចាប់យករួមមាន ម៉ូតូ ៧៨ គ្រឿង, រថយន្ត ៤ គ្រឿង, ប្រាក់កម្ពុជា ១៧៨.៨៦៥.១០០ រៀល, ប្រាក់វៀតណាម ៥៥០.០០០ ដុង, ប្រាក់ថៃ ៦១០ បាត, ប្រាក់អាមេរិក ៤៥.៨៧០ ដុល្លារ (**ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២**) ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៧ ដីកា = មនុស្ស ៧ នាក់ (ប្រុស) ជនជាតិខ្មែរ ។

**ជាមួយនេះ:** មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី ខេត្ត នៅក្នុងខែធ្នូ ឆ្នាំ២០១៤ នេះ សរុបចំនួន ៦១ សំណាក = ៥១ ករណី ។ ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន មាន ៥៨ សំណាក = ៦១ ករណី = ៩៥,០៩ % គឺ :**
  - មេតំហ្វេតាមីន ICE ៤៦ សំណាក = ៧៥,៤០ %
  - មេតំហ្វេតាមីន WY ១០ សំណាក = ១៦,៣៩ %
  - កញ្ឆា ០២ សំណាក = ៣,២៧ %
- **សំណាកអវិជ្ជមានសារធាតុញៀន ០៣ សំណាក = ០ ករណី = ០៤,៩១ %**

**ក្រៅពីការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន** មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានផ្តល់នូវ តេស្តពិនិត្យទឹកនោមរកសារធាតុមេតំហ្វេតាមីន ចំនួន ៨០០ តេស្ត ជូនដល់ក្រសួងសុខាភិបាល និង ៤០០ តេស្ត ជូនដល់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

## ***២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុង ខែធ្នូ ឆ្នាំ២០១៤ នេះ មានដូចតទៅ ៖

- សារធាតុគីមីចម្រុះ ដែលពាក់ព័ន្ធនឹងតារាង ទីIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សរុបចំនួន

**៨២៣.៧៩៥** គ.ក្រ ក្នុងនោះ ៖

- សារធាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ៦២៨.៣៦៥ គ.ក្រ
- សារធាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ១៩៥.៤៣០ គ.ក្រ

- ឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដែលនាំចូលដោយក្រសួងសុខាភិបាល និងពាក់ព័ន្ធជាមួយតារាង II, តារាង III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ៥៣ គ.ក្រ ១.០៨៦ ក្រាម ៦០០ មិល្លីក្រាម

**ជាមួយនេះ អគ្គលេខាធិការដ្ឋាន** អ.ជ.ប.គ.ញ បាន ៖

- ស្នើសុំទៅអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ដើម្បីចេញដីកាប្រគល់សារធាតុគីមី ចំនួន ១៤ មុខ ទម្ងន់ ១៨ តោន ៩០០ គីឡូក្រាម ដែលសមត្ថកិច្ចអនុវត្តច្បាប់រឹបអូស និងរក្សាទុកនៅកំពង់ផែស្វយ័ត ខេត្តព្រះសីហនុ ប្រគល់ជូនទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីគ្រប់គ្រងបន្ត និងចាត់ចែងសារធាតុគីមីទាំងនោះតាមសមត្ថកិច្ច
- សហការជាមួយអង្គការ UNODC ដើម្បីរៀបចំបែបបទបញ្ជូនសំណាកម្សៅវល្លិរមៀត ទៅធ្វើការវិភាគនៅមន្ទីរពិសោធន៍របស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ឱ្យបានច្បាស់លាស់ថាតើនៅក្នុងម្សៅនោះ មានផ្ទុកនូវសារធាតុអ្វីខ្លះ
- បន្តការរៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅក្នុំកន្លងមក។

## ២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជាប់ព្រំដែន

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- បន្តយកចិត្តទុកដាក់ជំរុញកិច្ចប្រជុំទ្វេភាគីថ្នាក់ខេត្ត ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ឡាវ និង ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន
- ពិនិត្យនិងរៀបចំកសាងផែនការសកម្មភាព ដែលគាំទ្រដល់លិខិតនៃកិច្ចព្រមព្រៀង (LOA) រវាងកម្ពុជា ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមតំបន់ព្រំដែន កម្ពុជា ថៃ នៅឆ្នាំ២០១៥ ។

## ២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- សម្របសម្រួលជូនឯកឧត្តមអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រតិភូអមដំណើរចូលរួមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៣ ស្តីពីបញ្ហាគ្រឿងញៀន កាលពីថ្ងៃទី ០១-០៤ ខែធ្នូ ឆ្នាំ ២០១៤ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី
- សម្រួលសម្រួលជាមួយ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តច្បាប់អាស៊ាន បូក ៣ ស្តីពីការប្រឆាំងថ្នាំញៀន ATS និងសារធាតុផ្សេងៗទៀត ដែលបានប្រព្រឹត្តទៅនៅប្រទេសថៃ នាថ្ងៃទី១៩-៣០ ខែមករា ឆ្នាំ២០១៤ ។

## ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងនិងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យឲ្យមានប្រសិទ្ធភាព អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- បន្តពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយបានឯកភាពប្រគល់ជូន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យលើមាត្រា៩ នៃសេចក្តីព្រាងអនុក្រឹត្យនេះ ដែលពាក់ព័ន្ធទៅនឹងបញ្ហាថវិកាសម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន

- បន្តការរៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤
- បន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តពាក់ព័ន្ធ ដើម្បីធ្វើការកែសម្រួលសមាសភាពរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

ដោយឡែក នៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមប្រជុំជាមួយគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីជំរុញអនុគណៈកម្មការទាំង៤ ដែលបានបង្កើតរួចហើយ ឱ្យអនុវត្តផែនការសកម្មភាពខាងលើទទួលបាននូវប្រសិទ្ធភាព និងចាត់តាំងអនុវត្តបន្តរហូតដល់អាជ្ញាធរថ្នាក់មូលដ្ឋានខណ្ឌ សង្កាត់ ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែមករា ឆ្នាំ២០១៥

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តសម្របសម្រួល ជំរុញអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម ៖

### ១. *ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន*

***១.១.*** ផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីយុទ្ធសាស្ត្រជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

***១.២.*** ត្រៀមរៀបចំការពិនិត្យ និងវាយតម្លៃជ្រើសរើសផ្ទាំងគំនូរជ័យលាភី ដើម្បីប្រកាសលទ្ធផលនិងផ្តល់រង្វាន់ ដល់សិស្សជ័យលាភី ដែលពូកែគូរគំនូរប្រឆាំងគ្រឿងញៀន នៅខេត្តកោះកុង នាថ្ងៃទី ២៨-២៩ ខែធ្នូ ឆ្នាំ២០១៤

***១.៣.*** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន

***១.៤.*** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងវិស័យឯកជន ក្នុងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផលស៊ីហ្សា និងបារីអេឡិចត្រូនិច នៅតាមរាជធានី ខេត្តទូទាំងប្រទេស

***១.៥.*** បន្តការពិភាក្សាលើខ្លឹមសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងជាមួយដៃគូពាក់ព័ន្ធនានា (ការអប់រំត្រូវមានឯកសារ ឧបករណ៍ សម្ភារៈដើម្បីឱ្យសិស្សឆាប់យល់ដឹង និងងាយទទួលយកបាន)

**១.៦.** បន្តជំរុញការពិភាក្សាលើការរៀបចំសាលារៀនបៃតង ( សាលារៀនគ្មានគ្រឿងញៀន )

**១.៧.** សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស

**១.៨.** បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា

**១.៩.** បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលអប់រំពីបញ្ហាគ្រឿងញៀន នៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និង នៅតាមសហគមន៍

**១.១០.** សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្តរៀបចំកម្មវិធីប្រគំតន្ត្រីអប់រំពីបញ្ហាគ្រឿងញៀន

**១.១១.** ជំរុញសកម្មភាពចែកចាយឯកសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនឱ្យកាន់តែសកម្មថែមទៀតនៅតំបន់គោលដៅសំខាន់ៗ ដើម្បីឱ្យអ្នករងគ្រោះអាចទៅទទួលយកសេវាព្យាបាលនៅមន្ទីរពេទ្យបង្អែក ឬ មណ្ឌលសុខភាពដែលនៅជិត ។

## ២. *ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន*

**២.១.** ត្រៀមទស្សនកិច្ចសិក្សាស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ សម្រាប់មន្ត្រីកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅខេត្តចាន់បុរី ខេត្តរ៉ាក់យ៉ង និង ខេត្តសាកែវ ប្រទេសថៃ ពីថ្ងៃទី១៣-១៦ ខែមករា ឆ្នាំ២០១៥ (មន្ត្រីពាក់ព័ន្ធ ចំនួន ២២ រូប)

**២.២.** ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅខេត្តបន្ទាយមានជ័យ សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផលនៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

**២.៣.** បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

**២.៤.** បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

**២.៥.** បង្កើនសកម្មភាពអប់រំណែនាំដល់អ្នករងគ្រោះដោយសារគ្រឿងញៀន ឱ្យស្ម័គ្រចិត្តទៅទទួលយកសេវាបន្សាប ព្យាបាលភាពញៀនគ្រឿងញៀន នៅកន្លែងផ្តល់សេវាដែលបានរៀបចំ ។

**២.៦.** បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញការរៀបចំកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ ឱ្យបានឆាប់រហ័ស

**២.៧.** ជំរុញឱ្យអនុគណៈកម្មការអប់រំ នៃគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត អំពីកម្មវិធីផ្តល់សេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងរបស់អង្គការមិត្តសំឡាញ់

**២.៨.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួងសុខាភិបាល គណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ត្រូវសហការគ្នាឱ្យបានជិតស្និទ្ធថែមទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាល (អង្គការ ខាន់ណា អង្គការមិត្តសំឡាញ់ ។ល។) និងចុះពន្យល់ណែនាំ បកស្រាយឱ្យមានការយល់ដឹងច្បាស់លាស់ថែមទៀតពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីម្ទុល/ស៊ីរ៉ាំង

**២.៩.** រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការ និង តុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ។

## ៣. *ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់*

**៣.១.** បន្តចូលរួមសហការជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ នៅតាមយោធភូមិភាគ និងវរការពារព្រំដែន

**៣.២.** បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ សម្រាប់ខែមករា ឆ្នាំ២០១៥

**៣.៣.** រៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមច្រកអាកាសយានដ្ឋានអន្តរជាតិ

**៣.៤.** សម្របសម្រួលជូនអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីចាត់បញ្ជូននាយនគរបាលទៅចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមេគង្គ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់កិច្ចសហប្រតិបត្តិការពហុភាគី ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងប៉េកាំង ប្រទេសចិន ពីថ្ងៃទី២០-២១/០១/២០១៥

**៣.៥.** ត្រៀមចូលរួមសិក្ខាសាលាអនុតំបន់ ស្តីពីការអភិវឌ្ឍនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ប្រភពព័ត៌មានគ្រឿងញៀនក្នុងតំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ២៧-២៨ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន

**៣.៦.** សហការ ឧបត្ថម្ភ និងជំរុញមន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល បំប៉ន ជំនាញស្តីពីការស្រាវជ្រាវ ស៊ើបអង្កេត និងការកសាងឯកសារសំណុំរឿង នីតិវិធីក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដល់មន្ត្រីនគរបាល ដែលមានភារកិច្ចពាក់ព័ន្ធនៅតាមបណ្តាខេត្តគោលដៅ

**៣.៧.** រៀបចំប្រជុំដកបទពិសោធន៍ លើករណីជួញដូរគ្រឿងញៀនដែលបង្ក្រាបកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ និងការប្រើប្រាស់គ្រឿងញៀននៅតាមផ្ទះសំណាក់

**៣.៨.** ធ្វើលិខិតស្នើសុំទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យលទ្ធភាពក្នុងការបំពេញបន្ថែមក្របខណ្ឌនគរបាលនៅថ្នាក់ប៉ុស្តិ៍រដ្ឋបាល

**៣.៩.** បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ជាមួយក្រសួងយុត្តិធម៌

***៣.១០.*** សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ធ្វើសម្រង់ទិន្នន័យឧប្បត្តិហេតុនៃបទល្មើសនានា (ទាំងបទឧក្រិដ្ឋ បទរំលោភបំពាន អំពើហឹង្សា អំពើអនាចារ លួចឆក់ប្លន់ ។ល។) ក្នុងឆ្នាំ២០១៤ ដែលបាន កើតឡើងដោយសារគ្រឿងញៀន និងបទល្មើសគ្រឿងញៀនដែលប្រព្រឹត្តដោយ ឬពាក់ព័ន្ធនឹងនគរបាល យោធា

***៣.១១.*** ជំរុញការអនុវត្តវិធានការទប់ស្កាត់ ការផលិត ការជួញដូរ ការប្រើប្រាស់គ្រឿងញៀននៅថ្នាក់មូលដ្ឋាន ឱ្យបានសកម្មដូចភ្លៀងរលឹម

***៣.១២.*** បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រ នៅនឹងកន្លែង (អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣) និងការបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រចល័ត (E-Learning)

***៣.១៣.*** ចុះពង្រឹង តាមដានការអនុវត្តច្បាប់ និងការអនុវត្តសាលក្រមតុលាការ របស់មន្ត្រីអនុវត្តន៍ច្បាប់ នៅតាមរាជធានី-ខេត្ត គោលដៅ ។

***៣.១៤.*** រៀបចំផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន សម្រាប់ឆ្នាំ២០១៥ ។

## ***៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ***

***៤.១.*** រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់

***៤.២.*** បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

***៤.៣.*** សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

***៤.៤.*** រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ***៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន***

***៥.១.*** សម្របសម្រួលជាមួយប្រទេសថៃ ឡាវ វៀតណាម ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងថ្នាក់ខេត្តនិងខេត្ត ស្រុកនិងស្រុកជាប់ព្រំដែនកម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដោយមានការចូលរួមពីផ្នែកកងទ័ព

***៥.២.*** ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ / កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម

***៥.៣.*** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.៣ ទៅកាន់ប្រទេសឡាវ និងប្រទេសវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** ចូលរួមកិច្ចប្រជុំមន្ត្រីសម្របសម្រួលថ្នាក់ជាតិ សម្រាប់ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រីនៃបណ្តាប្រទេសហត្ថលេខីក្នុងមហាអនុតំបន់ទន្លេមេគង្គ (MOU) ស្តីពីបញ្ហាគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហាណូយ (វៀតណាម) នាថ្ងៃទី១៥-១៦ ខែមករា ឆ្នាំ២០១៥

**៦.២.** សម្របសម្រួលជូនមន្ត្រីកម្ពុជា ចំនួន ២២ រូប ដើម្បីទៅទស្សនកិច្ចសិក្សាស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដែលនឹងប្រព្រឹត្តទៅនៅខេត្តចាន់បុរី ខេត្តរ៉ាក់យ៉ង និង ខេត្តសាកែវ ប្រទេសថៃ ពីថ្ងៃទី១៣-១៦ ខែមករា ឆ្នាំ២០១៥

**៦.៣.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចាត់បញ្ជូននាយនគរបាល នៃអគ្គស្នងការនគរបាលជាតិទៅចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមេគង្គ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់កិច្ចសហប្រតិបត្តិការពហុភាគី ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងប៉េកាំង ប្រទេសចិន ពីថ្ងៃទី២០-២១/០១/២០១៥

**៦.៤.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាអនុតំបន់ ស្តីពីការអភិវឌ្ឍនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ប្រភពព័ត៌មានគ្រឿងញៀនក្នុងតំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ២៧-២៨ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន

**៦.៥.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន

**៦.៦.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ពីគម្រោង PATROL របស់អង្គការ UNODC

**៦.៧.** សម្របសម្រួលរៀបចំដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៧.១.** ត្រៀមរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.២.** ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥

**៧.៣.** បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.៤.** ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.៥.** ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន

**៧.៦.** ជំរុញការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយនិងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន

**៧.៧.** បន្តការកែសម្រួលសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងាព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

**៧.៨.** បន្តជំរុញការរៀបចំយន្តការគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ពីថ្នាក់រាជធានីហូតដល់ ខណ្ឌ សង្កាត់ ដើម្បីចូលរួមចំណែកក្នុងការគាំទ្រកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ដោយធ្វើសកម្មភាពនៅតំបន់គោលដៅសំខាន់ៗ

**៧.៩.** ជំរុញការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាគ្រឿងញៀននៅក្នុងពន្ធនាគារ

**៧.១០.** រៀបចំកម្មវិធីផ្សព្វផ្សាយអំពី អនុសញ្ញាអន្តរជាតិស្ដីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួងស្ថាប័នដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.១១.** រៀបចំកម្មវិធីផ្សព្វផ្សាយអំពី ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

"ដើម្បីជូនជ្រាប"

- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្ដីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ